# ច្បាប់ស្ដីពី
# អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម

Bloomberg Philanthropies | DATA FOR HEALTH INITIATIVE | Vital Strategies | Global Health Advocacy Incubator

**សណ្ឋាគារហ្គាឌិន ស៊ីធី - រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣**

ដោយ ឧត្តមសេនីយ៍ឯក បណ្ឌិត គុប នេត អគ្គនាយក

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ

## សាវតានៃការងារតាក់តែងច្បាប់

- ថ្ងៃទី៣០/០៤/២០១៨ ៖ **បង្កើតក្រុមការងារ**តាក់តែងសេចក្ដីព្រាងច្បាប់**ស្ដីពីអត្រានុកូលដ្ឋាន** ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម (សេចក្ដីសម្រេចលេខ០៤៧ សសរ.គជដអ របស់ គ.ជ.ដ.អ)
- ថ្ងៃទី០១/០៧/២០២៣ ៖ ច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ **នស/រកម/០៧២៣/០០៩**
- **សមាសភាពក្រុមការងារ** ៖ ក្រុមការងារដឹកនាំដោយ
  - **លោកជំទាវ ចាន់ សុទ្ធាវី** រដ្ឋលេខាធិការប្រចាំការ ក្រសួងយុត្តិធម៌ **(ប្រធាន)**
  - **ឯកឧត្តម សន្តិបណ្ឌិត ម៉ៅ ច័ន្ទតារា** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ **(អនុប្រធាន)**
  - សមាសភាពក្រុមការងារតាក់តែងសេចក្ដីព្រាងច្បាប់ **១៤រូប**
  - អ្នកពាក់ព័ន្ធចូលរួមសរុប **៦៧រូប** (មកពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូ)



## រចនាសម្ព័ន្ធនៃច្បាប់

"ច្បាប់នេះចែកចេញជា ១២ជំពូក និង ១៨២មាត្រា"

- ជំពូកទី១. បទប្បញ្ញត្តិទូទៅ
- ជំពូកទី២. ការចុះបញ្ជីអត្រានុកូលដ្ឋាន
- ជំពូកទី៣. ស្ថិតិអត្រានុកូលដ្ឋាន
- ជំពូកទី៤. ការចុះបញ្ជីស្នាក់នៅ
- ជំពូកទី៥. ការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- ជំពូកទី៦. ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន
- ជំពូកទី៧. ការប្រើប្រាស់ទិន្នន័យ ការការពារឯកជនភាពបុគ្គល និងសន្តិសុខទិន្នន័យ
- ជំពូកទី៨. កម្រៃសេវា
- ជំពូកទី៩. ការត្រួតពិនិត្យ និងអធិការកិច្ច
- ជំពូកទី១០. ទោសប្បញ្ញត្តិ
- ជំពូកទី១១. អន្តរប្បញ្ញត្តិ
- ជំពូកទី១២. អវសានប្បញ្ញត្តិ។

# ជំពូកទី១.
# បទប្បញ្ញត្តិទូទៅ



## បទប្បញ្ញត្តិទូទៅ - មាត្រា១-៣

- **មាត្រា១ - គោលបំណង**
  ច្បាប់នេះកំណត់អំពីវិធាន និងនីតិវិធីក្នុងគោលបំណង៖
  – ធានាឱ្យមានការចុះបញ្ជីអត្រានុកូលដ្ឋាន **ជាកាតព្វកិច្ច ជាសកល ដោយជាប់លាប់ និងជាអចិន្ត្រៃយ៍**
  – ធានាឱ្យមានការចុះបញ្ជីអត្តសញ្ញាណបុគ្គល **ជាសកល ដោយជាប់លាប់ និងជាអចិន្ត្រៃយ៍**
  – ធានាការចុះបញ្ជីស្នាក់នៅ **ជាកាតព្វកិច្ច ជាសកល ដោយជាប់លាប់ និងជាអចិន្ត្រៃយ៍**
  – ធានាឱ្យមនុស្សគ្រប់រូបមានអត្តសញ្ញាណខាងផ្លូវច្បាប់តាមរយៈការចុះបញ្ជីអត្រានុកូលដ្ឋាន និងការចុះបញ្ជីអត្តសញ្ញាណ ដោយផ្តល់ចំពោះបុគ្គលម្នាក់ៗ នូវលេខសម្គាល់អត្តសញ្ញាណបុគ្គល
  – ធានានូវការគោរពសិទ្ធិមនុស្ស ការទទួលបានសេវាគ្រប់ប្រភេទ ហើយជាមូលដ្ឋានសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ និងការតាមដានភាពរីកចម្រើននៃសង្គម។
- **មាត្រា២ - វិសាលភាព**
  អនុវត្តចំពោះ**ជនគ្រប់រូប**ដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរដែលរស់នៅបរទេស។
- **មាត្រា៣ - និយមន័យ**
  វាក្យសព្ទសំខាន់ៗ មានកំណត់និយមន័យក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ។



# ជំពូកទី២.
# ការចុះបញ្ជីអត្រានុកូលដ្ឋាន

## វិធានទូទៅ និងបញ្ជីអត្រានុកូលដ្ឋាន - មាត្រា៤-៦

- **មាត្រា៤ - ព្រឹត្តិការណ៍ជីវិតដែលតម្រូវឱ្យចុះបញ្ជី**
  - ព្រឹត្តិការណ៍ជីវិតដែលតម្រូវឱ្យចុះបញ្ជីរួមមាន (១) **កំណើតរស់ (២) មរណភាព និង (៣) អាពាហ៍ពិពាហ៍**
  - ព្រឹត្តិការណ៍ជីវិតផ្សេងទៀតក៏ត្រូវចុះបញ្ជីផងដែរ រួមមានការទទួលស្គាល់កូន ការបញ្ជាក់អំពីនត្តិភាពនៃបុត្តភាព ការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព សុំកូន ការកាត់កាល់កូនសុំ ការលែងលះ មោឃភាពអាពាហ៍ពិពាហ៍ ការលុបចោលអាពាហ៍ពិពាហ៍ និងព្រឹត្តិការណ៍ជីវិតផ្សេងទៀត ដែលច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតតម្រូវឱ្យចុះបញ្ជី។
- **មាត្រា៥ - បញ្ជីអត្រានុកូលដ្ឋាន**
  - បញ្ជីអត្រានុកូលដ្ឋានរួមមាន (១) បញ្ជីកំណើតរស់ (២) បញ្ជីមរណភាព និង (៣) បញ្ជីអាពាហ៍ពិពាហ៍។
- **មាត្រា៦ - ទម្រង់បញ្ជីអត្រានុកូលដ្ឋាន**
  - បញ្ជីអត្រានុកូលដ្ឋានអាចរក្សាទុកក្នុងទម្រង់ជាក្រដាស (paper) និង/ឬទម្រង់អេឡិចត្រូនិក (electronic)។



## មន្ត្រីអត្រានុកូលដ្ឋាន - មាត្រា៧-១១

**មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ**
(អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម)

- **មន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត**
  (អភិបាលរាជធានី ខេត្ត)
  - **មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ**
    (អភិបាលក្រុង ស្រុក ខណ្ឌ)
    - **មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់**
      (មេឃុំ ចៅសង្កាត់)
- **មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាង**
  (ស្ថានទូត/ស្ថានកុងស៊ុល)





## សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋាន - មាត្រា១២-១៦

**ថ្នាក់ជាតិ (មាត្រា១២)**
- គ្រប់គ្រង និងរក្សាទុកបញ្ជីអត្រានុកូលដ្ឋាន
- ពិនិត្យសម្រេច និងអនុញ្ញាតឱ្យកែតម្រូវទិន្នន័យអត្រានុកូលដ្ឋាន ឬអនុញ្ញាតឱ្យចុះបញ្ជីឡើងវិញ
- ចេញសេចក្ដីចម្លងសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍

**ថ្នាក់រាជធានី ខេត្ត (មាត្រា១៣)**
- ចេញសេចក្ដីចម្លងសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍
- កែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន

**ថ្នាក់ក្រុង ស្រុក ខណ្ឌ (មាត្រា១៤)**
- ចេញសេចក្ដីចម្លងសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍
- កែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន

**ថ្នាក់ឃុំ សង្កាត់ (មាត្រា១៥)**
- អនុវត្តការចុះបញ្ជីអត្រានុកូលដ្ឋាន រួមបញ្ចូលទាំងការចេញសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ អនុញ្ញាតឱ្យបូជា/បញ្ចុះសព
- ការកែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន
- កត់ត្រា កែតម្រូវ ឬធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសេចក្ដីសម្រេចរបស់តុលាការ ឬតាមការសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់លើ




**ប្រចាំស្ថានតំណាង (មាត្រា១៦)**
- អនុវត្តការចុះបញ្ជីអត្រានុកូលដ្ឋាន
- ចេញសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍
- កែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន

## លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល (UIC) - មាត្រា២៦ & មាត្រា១៤២



- **បុគ្គលគ្រប់រូប** ដែលបានកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបុគ្គលជាប្រជាពលរដ្ឋខ្មែរដែលបាន**កើតនៅក្រៅប្រទេស** ត្រូវបានផ្តល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល (UIC) តាមរយៈការស្នើសុំចុះបញ្ជីកំណើតរស់ (មាត្រា២៦)
- លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល ត្រូវបានផ្តល់ជូនបុគ្គលម្នាក់ៗជាអចិន្ត្រៃយ៍ សម្រាប់ប្រើប្រាស់ **រហូតដល់បុគ្គលនោះទទួលមរណភាព** (មាត្រា១៤២)

**មន្ត្រីអត្រានុកូលដ្ឋាន ឃុំ សង្កាត់ និងប្រចាំស្ថានតំណាង**

ស្នើសុំលេខកូដ UIC →

ប្រព័ន្ធអត្តសញ្ញាណប្រជាជន (IPIS)

← ទទួលបានលេខកូដ UIC

**មជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន (NCPIM)**



## ទីកន្លែងចុះបញ្ជី៖ កំណើតរស់ និងមរណភាព

| អនុក្រឹត្យលេខ១០៣ (ឆ្នាំ២០០០) | ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម (ឆ្នាំ២០២៣, មាត្រា១៨ & មាត្រា៤២) |
|---|---|
| **ការចុះបញ្ជីកំណើត៖**<br>▪ ឃុំ សង្កាត់នៃលំនៅដ្ឋានរបស់ឪពុក ម្តាយ | **ការចុះបញ្ជីកំណើត (មាត្រា១៨)៖**<br>▪ ឃុំ សង្កាត់ដែលកំណើតរស់បានកើតឡើង<br>▪ ឃុំ សង្កាត់ដែលអ្នករាយការណ៍ស្នាក់នៅ<br>▪ កន្លែងផ្សេងទៀត (កំណត់ដោយក្រសួងមហាផ្ទៃ) |
| **ការចុះបញ្ជីមរណភាព៖**<br>▪ ឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់មរណជន | **ការចុះបញ្ជីមរណភាព (មាត្រា៤២)៖**<br>▪ ឃុំសង្កាត់ដែលព្រឹត្តិការណ៍មរណភាពបានកើតឡើង<br>▪ ឃុំ សង្កាត់ដែលមរណជនស្នាក់នៅ<br>▪ កន្លែងផ្សេងទៀត (កំណត់ដោយក្រសួងមហាផ្ទៃ) |
| មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ អាចស្នើសុំគោលការណ៍ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការបង្កើតការិយាល័យចុះបញ្ជីអត្រានុកូលដ្ឋាននៅមូលដ្ឋានសុខាភិបាល ឬកន្លែងផ្សេងទៀត (មាត្រា១២)។ | |



## រយៈពេលសម្រាប់ការចុះបញ្ជី៖ កំណើតរស់ និងមរណភាព

| អនុក្រឹត្យលេខ១០៣ (ឆ្នាំ២០០០) | ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម (ឆ្នាំ២០២៣, មាត្រា១៩, ៣៨, ៣៩, ៤៣, ៦៤, ៦៥) |
|---|---|
| **ការចុះបញ្ជីកំណើត៖**<br>▪ កំណើត = ក្នុងអំឡុងពេល ៣០ថ្ងៃ<br>▪ ករណីលើស៣០ថ្ងៃ ត្រូវសុំចុះបញ្ជីបញ្ជាក់កំណើត។ | **ការចុះបញ្ជីកំណើត៖**<br>▪ **កំណើត** = ក្នុងអំឡុងពេល ៣០ថ្ងៃ **(មិនមានសំបុត្របញ្ជាក់កំណើតទៀតទេ)** (មាត្រា១៩)<br>▪ **ក្នុងរយៈពេលអនុគ្រោះ: ១ឆ្នាំ** ត្រូវផ្តល់ការបញ្ជាក់មូលហេតុដល់មន្ត្រីអត្រានុកូលដ្ឋាន (មាត្រា៣៨)<br>▪ **ហួសរយៈពេលអនុគ្រោះ: ១ឆ្នាំ** ត្រូវផ្តល់ (១) ការបញ្ជាក់មូលហេតុដល់មន្ត្រីអត្រានុកូលដ្ឋាន (២) ព័ត៌មាន ឬឯកសារបន្ថែមដូចជាសាក្សី ឬប័ណ្ណសុខភាព ឬព័ត៌មានផ្សេងទៀត (មាត្រា៣៩) |
| **ការចុះបញ្ជីមរណភាព៖**<br>▪ មរណភាព = ១៥ថ្ងៃ ឬចុះបញ្ជីនៅក្នុងឆ្នាំអនុវត្ត<br>▪ ករណីមរណភាពទុកឱ្យហួសឆ្នាំអនុវត្ត ត្រូវដាក់ពាក្យសុំទៅតុលាការ។ | **ការចុះបញ្ជីមរណភាព៖**<br>▪ មរណភាព = ១៥ថ្ងៃ (មាត្រា៤៣)<br>▪ **ក្នុងរយៈពេលអនុគ្រោះ: ១ឆ្នាំ** ត្រូវផ្តល់ការបញ្ជាក់មូលហេតុដល់មន្ត្រីអត្រានុកូលដ្ឋាន (មាត្រា៦៤)<br>▪ **ហួសរយៈពេលអនុគ្រោះ: ១ឆ្នាំ** ត្រូវផ្តល់ (១) ការបញ្ជាក់អំពីមូលហេតុដល់មន្ត្រីអត្រានុកូលដ្ឋាន (២) ព័ត៌មាន ឬឯកសារបន្ថែមដែលបញ្ជាក់អំពីមរណភាព (មាត្រា៦៥) |

# អ្នករាយការណ៍អំពី៖ កំណើតរស់ និងមរណភាព

| អ្នករាយការណ៍អំពីកំណើតរស់ ( មាត្រា២០ ) | អ្នករាយការណ៍អំពីមរណភាព ( មាត្រា៤៤ ) |
| --- | --- |
| ▪ ម្ដាយរបស់ទារក<br>▪ ឪពុករបស់ទារក<br>▪ អ្នកអាណាព្យាបាលទូទៅរបស់ឪពុកម្ដាយទារក<br>▪ ញាតិជានីតិជនដែលមើលថែទារក<br>▪ រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬអ្នកតំណាង ឬបុគ្គលផ្សេងទៀតដែលកំណត់ដោយច្បាប់នេះ ឬច្បាប់ផ្សេង។ | **<u>សម្រាប់មរណភាពរបស់អនីតិជន៖</u>**<br>▪ ម្ដាយ ឬឪពុក ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន<br>▪ ញាតិជានីតិជនរបស់មរណជន<br>▪ រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬអ្នកតំណាង ឬបុគ្គលផ្សេងទៀត<br>**<u>សម្រាប់មរណភាពរបស់នីតិជន៖</u>**<br>▪ សហព័ទ្ធរបស់មរណជន ញាតិជានីតិជនរបស់មរណជន<br>▪ រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬអ្នកតំណាង ឬបុគ្គលផ្សេងទៀត<br>**<u>សម្រាប់មរណភាពដោយសារមូលហេតុខុសប្រក្រតី៖</u>**<br>▪ បុគ្គល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ |



# នីតិវិធីចុះបញ្ជី៖ កំណើតរស់ និងមរណភាព

**នីតិវិធីចុះបញ្ជីកំណើតរស់**
**( មាត្រា២៣, ២៤, ២៥ )**

**<u>អ្នករាយការណ៍ត្រូវ៖</u>**

- ដាក់ពាក្យសុំចុះបញ្ជី និងឯកសារភ្ជាប់ (រួមមាន ៖ ពាក្យសុំចុះបញ្ជី + ឯកសារបញ្ជាក់អំពីកំណើតរស់ពីមូលដ្ឋានសុខាភិបាល + ឯកសារអត្តសញ្ញាណឪពុកម្ដាយ)
- ផ្ដល់នូវព័ត៌មានអប្បបរមាសម្រាប់ការចុះបញ្ជី (ភេទ ថ្ងៃខែឆ្នាំកំណើត និងទីកន្លែងកំណើតរបស់ទារក)

**<u>មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ត្រូវ៖</u>**

- ទទួលយកពាក្យសុំចុះបញ្ជី
- ពិនិត្យ ផ្ទៀងផ្ទាត់ និងចុះបញ្ជី។



**នីតិវិធីចុះបញ្ជីមរណភាព**
**( មាត្រា៥២, ៥៣, ៥៤ )**

**<u>អ្នករាយការណ៍ត្រូវ៖</u>**

- ដាក់ពាក្យសុំចុះបញ្ជី និងឯកសារភ្ជាប់ (រួមមាន៖ ពាក្យសុំចុះបញ្ជី + ឯកសារបញ្ជាក់អំពីមរណភាពពីមូលដ្ឋានសុខាភិបាល + ឯកសារអត្តសញ្ញាណមរណជន)
- ផ្ដល់នូវព័ត៌មានអប្បបរមាសម្រាប់ការចុះបញ្ជី (ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត ថ្ងៃខែឆ្នាំម៉ោងមរណភាព ទីកន្លែងមរណភាពរបស់មរណជន។ល។)

**មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ត្រូវ៖**

- ទទួលយកពាក្យសុំចុះបញ្ជី
- ពិនិត្យ ផ្ទៀងផ្ទាត់ និងចុះបញ្ជី។



# ការចុះបញ្ជីអាពាហ៍ពិពាហ៍

| អនុក្រឹត្យលេខ១០៣ ( ឆ្នាំ២០០០ ) | ច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ( ឆ្នាំ២០២៣, មាត្រា៦៧, ៦៩, ៧០ ) |
| --- | --- |
| ▪ ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងកិច្ចសន្យារៀបអាពាហ៍ពិពាហ៍ធ្វើឡើងនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៅលំនៅឋាន **ខាងនារី**<br><br>▪ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ត្រូវប្រកាសផ្សាយក្នុងរយៈពេល១០ថ្ងៃ។ ផុតរយៈពេលប្ដឹងជំទាស់ អាពាហ៍ពិពាហ៍អាចធ្វើទៅបាន។ | ▪ បុរសម្នាក់ និងនារីម្នាក់ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ទៅមន្ត្រីអត្រានុកូលដ្ឋាននៃ **ឃុំ សង្កាត់ដែលបុរស ឬនារីនោះរស់នៅ (មាត្រា៦៧)**<br><br>▪ ប្រសិនបើគ្មានការជំទាស់ក្នុង**រយៈពេល១០ថ្ងៃ** ( ការជូនដំណឹងជាសាធារណៈអំពីការរៀបអាពាហ៍ពិពាហ៍ ) អាពាហ៍ពិពាហ៍អាចធ្វើឡើងគ្រប់ពេលវេលា **ក្នុងរយៈពេល៦ខែ** គិតចាប់ពីថ្ងៃដាក់ពាក្យសុំ **(មាត្រា៦៩)**<br><br>▪ បុរស និងនារី ត្រូវចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ដែលបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍នោះ **(មាត្រា៧០)** |

## តួនាទីតុលាការក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន និងជូនដំណឹងអំពីសេចក្តីសម្រេច

**ការជូនដំណឹងសេចក្តីសម្រេចស្ថាពរ របស់តុលាការ (មាត្រា៧៨, ៨១, ៨៤, ៨៧, ៨៩, ៩០)**

- ការលែងលះ មោឃភាព លុបចោលអាពាហ៍ពិពាហ៍ (មាត្រា៧៨)
- បិតុភាព/មាតុភាព ការទទួលស្គាល់ ការសុំកូន (មាត្រា៨១)
- ការចុះបញ្ជីផ្តាច់មត៌ក (មាត្រា៨៤)
- ការកែតម្រូវបញ្ជីអត្រានុកូលដ្ឋាន (មាត្រា៨៧)
- ការប្តូរឈ្មោះ (មាត្រា៨៩)

**សមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន (មាត្រា៧៨, ៨១, ៨៤, ៨៧, ៨៩, ៩០)**

- ពិនិត្យ ផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពព័ត៌មាននៃការលែងលះ មោឃភាព លុបចោលអាពាហ៍ពិពាហ៍ ក្នុងបញ្ជីអាពាហ៍ពិពាហ៍ (មាត្រា៧៨)
- ពិនិត្យ ផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពព័ត៌មាននៃបិតុភាព/មាតុភាព ការទទួលស្គាល់ ការសុំកូន ក្នុងបញ្ជីកំណើត (មាត្រា៨១)
- ពិនិត្យ ផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពព័ត៌មាននៃការផ្តាច់មត៌ក ក្នុងបញ្ជីកំណើត (មាត្រា៨៤)
- ពិនិត្យ ផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពព័ត៌មាននៃការកែតម្រូវបញ្ជីអត្រានុកូលដ្ឋាន (មាត្រា៨៧) ឬការប្តូរឈ្មោះ (មាត្រា៨៩) ក្នុងបញ្ជីអត្រានុកូលដ្ឋាន






## បណ្តឹងមិនសុខចិត្តក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋាន - មាត្រា៩៨

- បុគ្គលដែលបានស្នើសុំទៅមន្ត្រីអត្រានុកូលដ្ឋានដើម្បីចុះបញ្ជីព្រឹត្តិការណ៍ជីវិត ឬកែតម្រូវបញ្ជីអត្រានុកូលដ្ឋាន ឬសំណើផ្សេងៗទៀត **អាចប្តឹងមិនសុខចិត្ត**និងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការឃឹតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានបាន
- បែបបទនិងនីតិវិធីនៃការប្តឹងមិនសុខចិត្ត ត្រូវកំណត់ដោយ**ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
- បណ្តឹងខាងលើនេះមិនរារាំងការ**ប្តឹងទៅតុលាការដោយផ្ទាល់**ឡើយ។



## តួនាទីរបស់វិស័យសុខាភិបាលក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន

- ការជូនដំណឹងអំពីកំណើតរស់ និងមរណភាព ដែលកើតឡើង**ក្នុងមូលដ្ឋានសុខាភិបាល** (មាត្រា២១ និងមាត្រា៤៥)
- ការជូនដំណឹងអំពីកំណើតរស់ និងមរណភាព ដែលកើតឡើង**ក្រៅមូលដ្ឋានសុខាភិបាល** (មាត្រា២២ និងមាត្រា៤៦)
- ការបញ្ជាក់វេជ្ជសាស្ត្រអំពី**មូលហេតុនៃមរណភាព**៖
  - មរណភាពដោយសារ**មូលហេតុប្រក្រតី** (មាត្រា៤៨)
  - មរណភាពដោយសារ**មូលហេតុខុសប្រក្រតី ឬគួរឱ្យសង្ស័យ** (មាត្រា៤៩)។

## ការជូនដំណឹងអំពីកំណើតរស់/មរណភាព ដែលកើតឡើងក្នុងមូលដ្ឋានសុខាភិបាល




**សម្គាល់៖** ចាត់ទុកថា **កើតក្នុងមូលដ្ឋានសុខាភិបាល** ករណីម្តាយនិងទារក បានទៅមូលដ្ឋានសុខាភិបាល **ក្នុងរយៈពេល៤៨ម៉ោង** ក្រោយទារកកើត (មាត្រា២១)



## ការជូនដំណឹងអំពីកំណើតរស់ ដែលកើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល




**សម្គាល់៖** ចាត់ទុកថា **កើតក្រៅក្នុងមូលដ្ឋានសុខាភិបាល** ករណីម្តាយនិងទារក មិនបានទៅមូលដ្ឋានសុខាភិបាល **ក្នុងរយៈពេល៤៨ម៉ោង** ក្រោយទារកកើត (មាត្រា២២)



## ការជូនដំណឹងអំពីមរណភាព ដែលកើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល



# ការបញ្ជាក់វេជ្ជសាស្ត្រ អំពីមូលហេតុនៃមរណភាព ក្នុងករណីមរណភាពប្រក្រតី

**១. នៅក្នុងមូលដ្ឋានសុខាភិបាល ឬតាមផ្លូវទៅមូលដ្ឋានសុខាភិបាល៖**

ប្រធាន ឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាល បំពេញលិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព (MCCD) (មាត្រា៤៨)

**២. ក្រៅមូលដ្ឋានសុខាភិបាល៖**

ប្រសិនបើមូលដ្ឋានសុខាភិបាលអាចកំណត់អំពីមូលហេតុនៃការស្លាប់បាន ប្រធានឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាល បំពេញលិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព (MCCD) ប្រសិនបើអាច (មាត្រា៤៨)។




***សម្គាល់៖***
- *MOH: ក្រសួងសុខាភិបាល*
- *ICD: ព័ត៌មានអំពីមូលហេតុនៃការស្លាប់*
- *MCCD: លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព*



# ការបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាពខុសប្រក្រតី ឬគួរឱ្យសង្ស័យ




***សម្គាល់៖***
- *MOH: ក្រសួងសុខាភិបាល*
- *ICD: ព័ត៌មានអំពីមូលហេតុនៃការស្លាប់*
- *MCCD: លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព*



# ជំពូកទី៣.
# ស្ថិតិអត្រានុកូលដ្ឋាន

## ស្ថិតិអត្រានុកូលដ្ឋាន ?

**១. ស្ថិតិអត្រានុកូលដ្ឋានជាអ្វី ?**

- **ស្ថិតិអត្រានុកូលដ្ឋាន** មានប្រភពមកពីទិន្នន័យ**អត្រានុកូលដ្ឋាន**។ ស្ថិតិអត្រានុកូលដ្ឋានសំដៅដល់**ស្ថិតិអំពីព្រឹត្តិការណ៍ជីវិត**របស់ប្រជាពលរដ្ឋ
- ព្រឹត្តិការណ៍សំខាន់ៗដែលកំណត់អំពីជីវិតរបស់បុគ្គលណាម្នាក់ ដែលគប្បីចងក្រងឯកសារជាសកលសម្រាប់គោលបំណង**ផ្លូវច្បាប់ រដ្ឋបាល និងស្ថិតិ** មានដូចជាកំណើតរស់ មរណភាព ទារកស្លាប់កើត ទារកកើតស្លាប់ អាពាហ៍ពិពាហ៍ ការលែងលះ។ល។

**២. សារសំខាន់នៃស្ថិតិអត្រានុកូលដ្ឋាន៖**

- ស្ថិតិអត្រានុកូលដ្ឋានអំពីកំណើតរស់ មរណភាព ទារកស្លាប់កើត អាពាហ៍ពិពាហ៍ និងការលែងលះ ផ្តល់នូវ**មូលដ្ឋានព័ត៌មាន**សម្រាប់រាជរដ្ឋាភិបាលក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្នែករដ្ឋបាល ការអប់រំ ការចាក់ថ្នាំបង្ការ និងរៀបចំអន្តរាគមន៍ផ្នែកគោលនយោបាយសុខភាពសាធារណៈ
- ដើម្បីលើកកម្ពស់សមិទ្ធផលផ្នែកសេដ្ឋកិច្ច សង្គម និងសុខភាពសាធារណៈ។



## គោលការណ៍ជាមូលដ្ឋាន នៃស្ថិតិអត្រានុកូលដ្ឋាន - មាត្រា៩៩

**ស្ថិតិអត្រានុកូលដ្ឋាន ត្រូវអនុវត្តតាមគោលការណ៍ជាមូលដ្ឋាន ដូចខាងក្រោម៖**

- ធានាដល់ការផលិតស្ថិតិអត្រានុកូលដ្ឋានប្រកបដោយគុណភាព ត្រឹមត្រូវ ពេញលេញ ទាន់ពេលវេលានិងអាចជឿជាក់បាន
- ធានាការផ្តល់ព័ត៌មានចាំបាច់អំពីស្ថិតិប្រជាជន ដើម្បីគាំទ្រដល់ការរៀបចំការងាររដ្ឋបាល និងការរៀបចំផែនការនានា។





## អាជ្ញាធរមានសមត្ថកិច្ច និងការទទួលខុសត្រូវ - មាត្រា១០០-១០១

**១. សមត្ថកិច្ចរបស់វិទ្យាស្ថានជាតិស្ថិតិ (មាត្រា១០០)**

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ មានសមត្ថកិច្ចដូចខាងក្រោម៖

- ប្រមូល កែច្នៃ ចងក្រង វិភាគ និងផលិតស្ថិតិអត្រានុកូលដ្ឋានសម្រាប់ជាតិទាំងមូល និងដោយបែងចែងទៅតាមទីតាំងភូមិសាស្ត្រនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បោះពុម្ព និងផ្សព្វផ្សាយស្ថិតិអត្រានុកូលដ្ឋាន។

**២. ប្រភពទិន្នន័យនៃស្ថិតិអត្រានុកូលដ្ឋាន (មាត្រា១០១)**

- ប្រភពទិន្នន័យនៃស្ថិតិអត្រានុកូលដ្ឋានបានមកពីការប្រមូលនៅក្នុងដំណើរការចុះបញ្ជីកំណើតរស់ មរណភាព អាពាហ៍ពិពាហ៍ ព្រឹត្តិការណ៍ជីវិតផ្សេងទៀត និងពីការកត់ត្រាទារកស្លាប់កើត
- វិទ្យាស្ថានជាតិស្ថិតិអាចប្រើប្រាស់នូវប្រភពទិន្នន័យខាងលើ និងព័ត៌មានផ្សេងទៀត ដើម្បីបំពេញបន្ថែមនូវព័ត៌មានអំពីអត្រានុកូលដ្ឋាន។

## ការបញ្ជូនព័ត៌មានអត្រានុកូលដ្ឋាន និងទារកស្លាប់កើត - មាត្រា១០២

១. ការបញ្ជូនព័ត៌មានអត្រានុកូលដ្ឋានពីក្រសួងមហាផ្ទៃ ទៅក្រសួងផែនការ៖

- ក្រសួងមហាផ្ទៃត្រូវធានាបញ្ជូន**ព័ត៌មានចាំបាច់ពីបញ្ជីអត្រានុកូលដ្ឋាន**ទៅវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ឱ្យបានទៀងទាត់និងទាន់ពេលវេលា
- ក្រសួងមហាផ្ទៃ**មិនត្រូវបញ្ជូនព័ត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណបុគ្គល**ដូចជាឈ្មោះ ពីបញ្ជីអត្រានុកូលដ្ឋានទៅវិទ្យាស្ថានជាតិស្ថិតិឡើយ
- ពេលវេលា បែបបទ និងព័ត៌មានដែលត្រូវបញ្ជូន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងផែនការ។

២. ការបញ្ជូនព័ត៌មានអត្រានុកូលដ្ឋានពីក្រសួងសុខាភិបាល ទៅក្រសួងផែនការ៖

- ក្រសួងសុខាភិបាលត្រូវធានាបញ្ជូនព័ត៌មានអំពី**ទារកស្លាប់កើត**ទៅវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ឱ្យបានទៀងទាត់និងទាន់ពេលវេលា
- ក្រសួងសុខាភិបាល**មិនត្រូវបញ្ជូនព័ត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណបុគ្គល**ដូចជាឈ្មោះរបស់ឪពុកម្តាយ ទៅវិទ្យាស្ថានជាតិស្ថិតិឡើយ
- ពេលវេលា បែបបទ និងព័ត៌មានដែលត្រូវបញ្ជូន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសុខាភិបាលនិងរដ្ឋមន្ត្រីក្រសួងផែនការ។






## ការចងក្រង បោះពុម្ព និងផ្សព្វផ្សាយស្ថិតិអត្រានុកូលដ្ឋាន - មាត្រា១០៣

១. វិទ្យាស្ថានជាតិស្ថិតិ ត្រូវបោះពុម្ពស្ថិតិអត្រានុកូលដ្ឋាន៖

- ទាន់ពេលវេលា
- ត្រឹមត្រូវ
- ពេញលេញ
- យ៉ាងហោចណាស់មួយឆ្នាំម្តង។

២. វិទ្យាស្ថានជាតិស្ថិតិ ត្រូវផ្សព្វផ្សាយ៖

- នៅលើគេហទំព័រ
- មធ្យោបាយសមស្របដទៃទៀត។








# ជំពូកទី៤.
# ការចុះបញ្ជីស្នាក់នៅ

## គោលការណ៍ជាមូលដ្ឋាន ការចុះបញ្ជីស្នាក់នៅ - មាត្រា១០៥

- ធានាការ**រាប់ចំនួនមនុស្ស និងធ្វើបច្ចុប្បន្នភាពអាសយដ្ឋាន**របស់បុគ្គលគ្រប់រូបដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែករក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ការងាររដ្ឋបាល និងការងាររៀបចំផែនការនានា
- ធានាថាបុគ្គលគ្រប់រូបមាន**សិទ្ធិក្នុងការចុះបញ្ជីស្នាក់នៅ**
- ពង្រឹងប្រសិទ្ធភាពនៃការបង្កើត**ប្រព័ន្ធប្រមូល និងគ្រប់គ្រងទិន្នន័យទាក់ទងនឹងការស្នាក់នៅ**របស់បុគ្គលគ្រប់រូបឱ្យបានត្រឹមត្រូវ ដែលមានលក្ខណៈឯកភាពនៅទូទាំងប្រទេស
- ធានាយកទិន្នន័យទាក់ទងនឹងការស្នាក់នៅធ្វើជាមូលដ្ឋានមួយ**សម្រាប់ការផ្តល់សេវាសាធារណៈ**។





## សមត្ថកិច្ចនិងមន្ត្រីចុះបញ្ជីស្នាក់នៅ - មាត្រា១០៦-១០៨

- ការចុះបញ្ជីស្នាក់នៅ និងការគ្រប់គ្រងការស្នាក់នៅស្ថិតនៅក្រោមសមត្ថកិច្ចរបស់**ក្រសួងមហាផ្ទៃ**
- មន្ត្រីចុះបញ្ជីស្នាក់នៅ គឺជា**នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់**។



**ការទទួលខុសត្រូវសំខាន់ៗរបស់មន្ត្រីចុះបញ្ជីស្នាក់នៅ៖**
- ពិនិត្យ កត់ត្រា និងចុះបញ្ជីស្នាក់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចេញឯកសារសម្គាល់ការស្នាក់នៅ
- កែតម្រូវ លុបបញ្ជីស្នាក់នៅ ធ្វើមោឃភាព និងដកហូតឯកសារសម្គាល់ការស្នាក់នៅ
- ចុះត្រួតពិនិត្យរដ្ឋបាលជាប្រចាំដល់លំនៅឋាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីពិនិត្យផ្ទៀងផ្ទាត់អំពីការប្រែប្រួលនៃសមាជិកដែលរស់នៅក្នុងលំនៅឋាននីមួយៗ សំដៅធ្វើបច្ចុប្បន្នភាពបញ្ជីស្នាក់នៅ និងការចុះបញ្ជីស្នាក់នៅឱ្យបានពេញលេញ
- លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិ និងកាតព្វកិច្ច។



## តើនរណាខ្លះត្រូវចុះបញ្ជីស្នាក់នៅ?

| លិខិតបទដ្ឋានគតិយុត្ត បច្ចុប្បន្ន | ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម (ឆ្នាំ២០២៣, មាត្រា១០៩, ១១០) |
|---|---|
| ▪ **បុគ្គលគ្រប់រូបលើកលែងតែ៖**<br>– ជនបរទេសមិនមែនអន្តោប្រវេសន៍<br>– ជនបរទេសដែលរស់នៅខុសច្បាប់<br>– កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ និងនគរបាលជាតិ ដែលរស់នៅប្រមូលផ្តុំក្នុងបន្ទាយ។<br>– អ្នកទាំងនោះអាចចុះឈ្មោះជាមួយគ្រួសាររៀងៗ ខ្លួនបាន។ | ▪ បុគ្គលគ្រប់រូបត្រូវចុះបញ្ជីស្នាក់នៅ (ពុំមានករណីលើកលែងទេ)<br>▪ បញ្ជីស្នាក់នៅអាចមានទម្រង់ជាក្រដាសនិង/ឬទម្រង់ជាអេឡិចត្រូនិក។ |

# ទីកន្លែងចុះបញ្ជីស្នាក់នៅ និងបុគ្គលទទួលខុសត្រូវស្នើសុំចុះបញ្ជីស្នាក់នៅ

| ទីកន្លែង/បុគ្គល | លិខិតបទដ្ឋានគតិយុត្ត បច្ចុប្បន្ន | ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម (ឆ្នាំ២០២៣, មាត្រា១១០, ១១១) |
|---|---|---|
| **ទីកន្លែង ចុះបញ្ជីស្នាក់នៅ** | ▪ លំនៅឋានអចិន្ត្រៃយ៍<br>▪ លំនៅឋានបណ្តោះអាសន្ន (រយៈពេលស្នាក់នៅតិចជាង ៦ខែ) | មាត្រា១១០៖<br>▪ បុគ្គលគ្រប់រូបត្រូវចុះបញ្ជីស្នាក់នៅ នៅតាមលំនៅឋានដែលខ្លួនកំពុងរស់នៅបច្ចុប្បន្ន ដើម្បីទទួលបានការទទួលស្គាល់ការស្នាក់នៅក្នុងលំនៅឋាននោះ<br>▪ បុគ្គលគ្រប់រូបអាចចុះបញ្ជីស្នាក់នៅតែមួយកន្លែង ទោះបុគ្គលនោះមានលំនៅឋានច្រើនជាងមួយក៏ដោយ។ |
| **បុគ្គល ទទួលខុសត្រូវស្នើសុំចុះបញ្ជីស្នាក់នៅ** | ▪ ជនគ្រប់រូបដែលជាអ្នកទទួលខុសត្រូវចម្បងនៃគេហដ្ឋាននីមួយៗ (អនុក្រឹត្យលេខ៧៣ ឆ្នាំ ១៩៩៧) | មាត្រា១១១៖<br>▪ អ្នកតំណាងនៃលំនៅឋាននីមួយៗ<br>▪ ម្ចាស់លំនៅឋាន ឬអ្នកឱ្យជួល ឬអ្នកតំណាងក្នុងករណីលំនៅឋានជាកម្មវត្ថុនៃការជួល<br>▪ ប្រធានអង្គភាព ឬអ្នកគ្រប់គ្រង ឬអ្នកតំណាង ក្នុងករណីលំនៅឋានដែលរស់នៅប្រមូលផ្តុំ<br>▪ អ្នកស្នាក់នៅជាក់ស្តែង<br>▪ បុគ្គលផ្សេងទៀត ឬប្រធានអង្គភាព ឬអ្នកគ្រប់គ្រង ឬអ្នកតំណាងដែលអនុញ្ញាតដោយច្បាប់នេះ ឬច្បាប់ផ្សេងទៀត។ |



# ឯកសារសម្គាល់ការស្នាក់នៅ និងលិខិតបញ្ជាក់ទីលំនៅ

| លិខិតបទដ្ឋានគតិយុត្ត បច្ចុប្បន្ន | ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម (ឆ្នាំ២០២៣, មាត្រា១១៤, ១១៥) |
|---|---|
| ▪ សៀវភៅស្នាក់នៅមួយ សម្រាប់ខ្នងផ្ទះមួយ<br>▪ ផ្តល់ជូនទៅមេគ្រួសារ | **ឯកសារសម្គាល់ការស្នាក់នៅ (មាត្រា១១៤)**<br>▪ ផ្តល់ជូនទៅឱ្យបុគ្គលដែលស្នើសុំចុះបញ្ជីស្នាក់នៅ<br><br>**បុគ្គលដែលអាចស្នើសុំលិខិតបញ្ជាក់ទីលំនៅ (មាត្រា១១៥)**<br>▪ សាមីខ្លួននៃលិខិតបញ្ជាក់ទីលំនៅ<br>▪ អ្នកតំណាងរបស់សាមីខ្លួននៃលិខិតបញ្ជាក់ទីលំនៅ និងតំណាងស្របច្បាប់.... |



# ការកែតម្រូវកំហុសក្នុងបញ្ជីស្នាក់នៅ

**១. បុគ្គលដែលអាចស្នើសុំកែតម្រូវ (មាត្រា១១៨)៖**

- សាមីខ្លួននៃបញ្ជីស្នាក់នៅ
- ឪពុក ឬម្តាយ
- អ្នកតំណាងស្របច្បាប់។

**២. ការកែតម្រូវកំហុសក្នុងបញ្ជីស្នាក់នៅ (មាត្រា១១៩)៖**

- មន្ត្រីចុះបញ្ជីស្នាក់នៅអាចកែតម្រូវកំហុសបាន ឬប្រសិនបើគ្មានឯកសារភ្ជាប់គ្រប់គ្រាន់ អាចបដិសេធសំណើបាន
- ត្រូវបញ្ជាក់មូលហេតុនៃការបដិសេធនោះជាលាយលក្ខណ៍អក្សរ
- បុគ្គលដែលបានស្នើសុំអាចប្តឹងមិនសុខចិត្តចំពោះការបដិសេធបាន។

**៣. បណ្តឹងមិនសុខចិត្ត (មាត្រា១២៣)៖**

- បុគ្គលដែលបានស្នើសុំ អាចប្តឹងមិនសុខចិត្តនឹងការចាត់ចែង ឬការសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីចុះបញ្ជីស្នាក់នៅ
- បែបបទនិងនីតិវិធីនៃការប្តឹងមិនសុខចិត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- បណ្តឹងខាងលើនេះ**មិនរាំងការប្តឹងទៅតុលាការដោយផ្ទាល់ឡើយ។**



# ជំពូកទី៥.
# ការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ



## អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

- **អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ** ជាឯកសារផ្លូវការមួយសម្រាប់បញ្ជាក់អំពីអត្តសញ្ញាណបុគ្គលម្នាក់ៗដែលមានសញ្ជាតិខ្មែរ ដោយមិនអនុញ្ញាតឱ្យធ្វើការផ្ទេរពីបុគ្គលមួយទៅបុគ្គលមួយទៀត ឬយកទៅបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សបានឡើយ (មាត្រា១២៩)។
- **គោលការណ៍ជាមូលដ្ឋាននៃការចុះបញ្ជី (មាត្រា១២៤)៖**
  - ធានាថា**បុគ្គលមានសញ្ជាតិខ្មែរ**មានសិទ្ធិក្នុងការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
  - ពង្រឹងប្រសិទ្ធភាពនៃការបង្កើតប្រព័ន្ធប្រមូល និងគ្រប់គ្រងទិន្នន័យទាក់ទងនឹងអត្តសញ្ញាណបុគ្គលដែលមានសញ្ជាតិខ្មែរឱ្យបានត្រឹមត្រូវ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT)
  - ទិន្នន័យទាក់ទងនឹងការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរអាចប្រើប្រាស់ជាមូលដ្ឋានក្នុងការផ្ទៀងផ្ទាត់ និងបញ្ជាក់ពីភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណរបស់បុគ្គលដែលមានសញ្ជាតិខ្មែរ។






## សមត្ថកិច្ច ការទទួលខុសត្រូវ និងទីកន្លែងនៃការចុះបញ្ជីអត្តសញ្ញាណបណ្ណ




- **ការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ (មាត្រា១២៥)**
- **មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែររួមមាន (មាត្រា១២៦)៖**
  - ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់
  - អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
  - ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
  - មន្ត្រីផ្សេងទៀត ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
- **ការទទួលខុសត្រូវសំខាន់ៗ របស់មន្ត្រីចុះបញ្ជី (មាត្រា១២៧)៖**
  - ពិនិត្យ កត់ត្រា ចុះបញ្ជី (ឬលើកចោល) ពាក្យសុំចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
  - ផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
  - រៀបចំបែបបទទាក់ទងនឹងការកែតម្រូវ មោឃភាព លុបចោល និងដកហូត ជូនទៅថ្នាក់លើ
- **ទីកន្លែងចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (មាត្រា១៣០)៖**
  - ឃុំ សង្កាត់នៃលំនៅឋានដែលសាមីខ្លួនកំពុងរស់នៅ រួមមាន៖
    - ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់
    - អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
    - ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត។ល។
  - ទីកន្លែងផ្សេងទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ការកែតម្រូវទិន្នន័យក្នុងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ - មាត្រា១៣៣

- **បុគ្គលម្នាក់ៗ អាចស្នើសុំកែតម្រូវទិន្នន័យក្នុងបញ្ជី និង អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរបាន ក្នុងករណីដែល៖**
  - បញ្ជីអត្រានុកូលដ្ឋាន ( ឧ. បញ្ជីកំណើត ) ត្រូវបានកែតម្រូវ ឬ
  - ព័ត៌មាននៅក្នុងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ខុសពីព័ត៌មាននៅក្នុងបញ្ជីអត្រានុកូលដ្ឋាន
  - ទទួលបានសញ្ជាតិខ្មែរហើយ តែមិនបានចុះបញ្ជីអត្រានុកូលដ្ឋាន។





## ការលុបបញ្ជី មោឃភាព និងការដកហូតអត្តសញ្ញាណបណ្ណ - មាត្រា១៣៤

- **ការលុបចោលបញ្ជីអត្តសញ្ញាណបណ្ណ៖**
  - អត្តសញ្ញាណបណ្ណដែលបានចុះបញ្ជីមិនស្របទៅតាមច្បាប់កំណត់
  - បុគ្គលបានស្លាប់
  - បុគ្គលបានបាត់បង់សញ្ជាតិខ្មែរ។
- **ការមោឃភាព ( សន្លឹក ) អត្តសញ្ញាណបណ្ណ៖**
  - អត្តសញ្ញាណបណ្ណត្រូវបានផ្តល់ជូនក្នុងលក្ខណៈខុសនីតិវិធីកំណត់ដោយច្បាប់
  - បុគ្គលប្រើប្រាស់អត្តសញ្ញាណបណ្ណលើសពីមួយ
  - បុគ្គលដែលបានចុះបញ្ជីបានទទួលមរណភាព
  - បុគ្គលបានបាត់បង់សញ្ជាតិខ្មែរ។
- **ការដកហូតអត្តសញ្ញាណបណ្ណ៖**
  - ប្រសិនបើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរត្រូវបានលុបចោល ឬ មោឃភាព អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរត្រូវបានដកហូត។





## ការបញ្ជូនទិន្នន័យទៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណ - មាត្រា១៣៥

- **ទិន្នន័យនៅក្នុងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរត្រូវបាន៖**
  - បញ្ជូនទៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន (NCPIM) ស្របតាមជំពូកទី៦ ស្តីពីប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន (IPIS) និង
  - ថែរក្សាទុកដោយសុវត្ថិភាពនៅក្នុងបញ្ជីប្រជាជន ស្របតាមគោលការណ៍ស្តីពីឯកជនភាព ដែលមានចែងនៅក្នុងជំពូកទី៧
  - ទិន្នន័យបុគ្គលត្រូវបានការពារ និងគ្រប់គ្រងដោយរដ្ឋ។



## បណ្តឹងមិនសុខចិត្តនឹងការចាត់ចែងរបស់មន្ត្រីចុះបញ្ជី - មាត្រា១៣៧

- បុគ្គលដែលបានស្នើសុំទៅមន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ **អាចប្តឹងមិនសុខចិត្ត** នឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- បែបបទនិងនីតិវិធីនៃការប្តឹងមិនសុខចិត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- បណ្តឹងខាងលើនេះ**មិនរារាំងការប្តឹង**ទៅតុលាការដោយផ្ទាល់ឡើយ។






# ជំពូកទី៦.
# ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន (IPIS)



## គោលការណ៍ជាមូលដ្ឋាន នៃប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន - មាត្រា១៣៨

- **ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន (IPIS) ត្រូវអនុវត្តតាមគោលការណ៍ជាមូលដ្ឋានដូចខាងក្រោម៖**
  - ធានាដល់ការប្រមូលផ្តុំទិន្នន័យប្រជាជនជាឌីជីថល
  - ធានាដល់គុណភាព និងគោលការណ៍ឯកត្តកម្មព័ត៌មានអត្តសញ្ញាណបុគ្គល និងធានាឱ្យស្ថាប័ន ឬបុគ្គលក្នុងការស្វែងរកទិន្នន័យពិតប្រាកដ
  - ធានាឱ្យបុគ្គលដែលមានសញ្ជាតិខ្មែរ និងបុគ្គលទាំងឡាយណាដែលកើត និង/ឬស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលតែមួយគត់ (UIC) និងជាអចិន្ត្រៃយ៍។



# តើប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន (IPIS) ជាអ្វី?

- **ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន (មាត្រា១៣៩)៖**
  - ជាប្រព័ន្ធស្នូលទិន្នន័យអត្តសញ្ញាណបុគ្គល
  - ភ្ជាប់ និងធ្វើអន្តរកម្មជាមួយប្រព័ន្ធ (១) ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន (២) ប្រព័ន្ធគ្រប់គ្រងការស្នាក់នៅ (៣) ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (៤) ប្រព័ន្ធគ្រប់គ្រងលិខិតឆ្លងដែន (៥) ប្រព័ន្ធគ្រប់គ្រងទិន្នន័យសញ្ជាតិ និង (៦) ប្រព័ន្ធផ្សេងទៀត។
- **ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជនមានមុខងារ (មាត្រា១៤០)៖**
  - បញ្ចូន និងធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់នូវទិន្នន័យអត្តសញ្ញាណបុគ្គលនៅក្នុងបញ្ជីប្រជាជន
  - បង្កើតលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល (UIC) ដោយស្វ័យប្រវត្តិ
  - ធ្វើអន្តរកម្មរវាង (១) ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន (២) ប្រព័ន្ធគ្រប់គ្រងការស្នាក់នៅ (៣) ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (៤) ប្រព័ន្ធគ្រប់គ្រងលិខិតឆ្លងដែន (៥) ប្រព័ន្ធគ្រប់គ្រងទិន្នន័យសញ្ជាតិ និង (៦) ប្រព័ន្ធផ្សេងទៀត ដើម្បីកត់ត្រា រក្សាទុក ធ្វើបច្ចុប្បន្នភាពទិន្នន័យ និងផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គលពីបញ្ជីប្រជាជន
  - បែងចែកទិន្នន័យអត្តសញ្ញាណបុគ្គលចេញពីបញ្ជីប្រជាជន។






# លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល (UIC)

- **លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល៖**
  - លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល (UIC) បង្កើតដោយប្រព័ន្ធ IPIS ដោយចៃដន្យ និងដោយស្វ័យប្រវត្តិ (មាត្រា១៤១)
  - លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលត្រូវបានផ្តល់ជូនបុគ្គលម្នាក់ៗ ជាអចិន្ត្រៃយ៍សម្រាប់ប្រើប្រាស់ រហូតដល់បុគ្គលនោះទទួលមរណភាព (មាត្រា១៤២)
  - បុគ្គលគ្រប់រូបនឹងត្រូវទទួលបានលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល នៅពេលធ្វើការស្នើសុំចុះបញ្ជីកំណើតរស់ ចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ចុះបញ្ជីអន្តោប្រវេសន៍ ឬចុះបញ្ជីសញ្ជាតិ (មាត្រា១៤២)
- **ការបិទលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល៖** នៅពេលចុះបញ្ជីមរណភាព ឬមានការក្លែងបន្លំការចុះបញ្ជី (មាត្រា១៤៣)
- **ការផ្អាកលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល៖** បាត់បង់សិទ្ធិក្នុងការស្នាក់នៅ ឬចេញ ចូល ក្នុងព្រះរាជាណាចក្រកម្ពុជា និងលះបង់សញ្ជាតិខ្មែរ (មាត្រា១៤៤)
- **ការបើកលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលឡើងវិញ៖** ក្នុងករណីយល់ឃើញថាមូលហេតុណាមួយនៃការបិទ ឬការផ្អាក មិនកើតឡើង (មាត្រា១៤៥)។





# តើបញ្ជីប្រជាជនគឺជាអ្វី?

- **បញ្ជីប្រជាជន (មាត្រា១៤៧)៖**
  - បញ្ជីប្រជាជន (Population Register) នៃប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន (IPIS) គឺជាប្រភពចម្បង និងតែមួយគត់នៃទិន្នន័យប្រជាជន
- **ទិន្នន័យអត្តសញ្ញាណបុគ្គល ក្នុងបញ្ជីប្រជាជន (មាត្រា១៤៨) រួមមាន៖**
  - លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល (UIC)
  - ព័ត៌មានជីវប្រវត្តិបុគ្គល (**ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត សញ្ជាតិ។ល។**)
  - ព័ត៌មានជីវមាត្រ (រូបថត ខ្ទាំដៃ ប្រស្រីភ្នែក)
  - ផ្សេងទៀត។



## មជ្ឈមណ្ឌលជាតិ និងអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន

- **មជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន (NCPIM) (មាត្រា១៥០)៖**
  - ទទួលខុសត្រូវគ្រប់គ្រង រក្សាទុក និងបែងចែកទិន្នន័យនៅក្នុងបញ្ជីប្រជាជនប្រកបដោយសុវត្ថិភាពបំផុត។
- **អាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន (NAPIM) (មាត្រា១៥១)៖**
  - ដឹកនាំ គ្រប់គ្រង និងធានាដល់ការរៀបចំ និងការធ្វើបច្ចុប្បន្នភាពនៃកំណត់ត្រាអត្តសញ្ញាណបុគ្គល និងការប្រើប្រាស់ទិន្នន័យ ដោយមាន NCPIM ជាសេនាធិការ។
  - ការរៀបចំ និងការប្រព្រឹត្តទៅនៃ NAPIM ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។





# ជំពូកទី៧.
# ការប្រើប្រាស់ទិន្នន័យ ការការពារឯកជនភាពបុគ្គល និងសន្តិសុខទិន្នន័យ



## សិទ្ធិទទួលបានព័ត៌មានបុគ្គល និងការប្រើប្រាស់ទិន្នន័យនៅក្នុងបញ្ជីប្រជាជន

- **បុគ្គលគ្រប់រូបមានសិទ្ធិ៖**
  - ទទួលបានព័ត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណបុគ្គលរបស់ខ្លួន (មាត្រា១៥២)
  - ទទួលបានសម្រង់ព័ត៌មានអត្តសញ្ញាណបុគ្គល (មាត្រា១៥៣)
  - កែតម្រូវព័ត៌មានអត្តសញ្ញាណបុគ្គល (មាត្រា១៥៤)។
- **អាជ្ញាធរមានសមត្ថកិច្ចនៃគ្រឹះស្ថានសាធារណៈអាចប្រើប្រាស់ទិន្នន័យនៅក្នុងបញ្ជីប្រជាជនសម្រាប់បំពេញមុខងារសាធារណៈ (មាត្រា១៥៦)**
  - ទិន្នន័យត្រូវមានកម្រិតត្រឹមវិសាលភាពដែលមានភាពចាំបាច់ និងសមាមាត្រទៅនឹងការប្រើប្រាស់ជាក់លាក់
  - ទិន្នន័យត្រូវចែករំលែកក្នុងលក្ខណៈមួយដែលធានាបាននូវការរក្សាការសម្ងាត់។
- **អ្នកផ្តល់សេវាសាធារណៈ និងឯកជន អាចប្រើប្រាស់បញ្ជីប្រជាជន ឬសមាសធាតុដទៃទៀតនៃប្រព័ន្ធអត្តសញ្ញាណប្រជាជន ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណ (មាត្រា១៥៦)**
  - អ្នកផ្តល់សេវាទទួលបានការឆ្លើយតប "ត្រឹមត្រូវ" ឬ "មិនត្រឹមត្រូវ"
  - ពុំមានការចែករំលែកព័ត៌មានអត្តសញ្ញាណបុគ្គល។



# ការផលិតស្ថិតិចេញពីបញ្ជីប្រជាជន - មាត្រា១៥៧

- **ការផលិតទិន្នន័យស្ថិតិចេញពីបញ្ជីប្រជាជន៖**
  - មជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន (NCPIM) អាចសម្រេចអនុញ្ញាត ឬបដិសេធចំពោះសំណើសុំប្រើប្រាស់ទិន្នន័យពីបញ្ជីប្រជាជន ដើម្បីផលិតស្ថិតិ
  - ប្រសិនបើអនុញ្ញាត ត្រូវមានកិច្ចព្រមព្រៀងរវាង NCPIM និងអ្នកស្នើសុំ ដើម្បីរក្សាឯកជនភាពបុគ្គល សន្តិសុខ និងការសម្ងាត់
  - ទិន្នន័យដែលផលិតចេញពីបញ្ជីប្រជាជន មិនគួរមានព័ត៌មានដែលអាចកំណត់អត្តសញ្ញាណរបស់បុគ្គលណាមួយឡើយ។





# បណ្តឹងមិនសុខចិត្ត - មាត្រា១៥៨

- បុគ្គលគ្រប់រូបមានសិទ្ធិប្តឹងមិនសុខចិត្ត ចំពោះសេចក្តីសម្រេច ឬការបដិសេធទាក់ទងនឹងសិទ្ធិទទួលបានព័ត៌មានអត្តសញ្ញាណបុគ្គល ដូចបានកំណត់នៅក្នុងមាត្រា១៥២ (សិទ្ធិទទួលបានព័ត៌មានអត្តសញ្ញាណបុគ្គល) ឬការកែតម្រូវសម្រង់ព័ត៌មាន ដូចបានកំណត់នៅក្នុងមាត្រា១៥៤ (ការកែតម្រូវសម្រង់ព័ត៌មាន) នៃច្បាប់នេះ។






# ការការពារឯកជនភាពបុគ្គល - មាត្រា១៥៩

- **ត្រូវរក្សាការសម្ងាត់ចំពោះ៖**
  - ការរក្សាការសម្ងាត់នៃព័ត៌មានឯកជន ដែលបានកត់ត្រានៅក្នុងបញ្ជីប្រជាជន បញ្ជីអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ បញ្ជីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងបញ្ជីអត្តសញ្ញាណបុគ្គលផ្សេងទៀត ត្រូវបានការពារ។
- **បញ្ជីឈ្មោះរបស់បុគ្គលដែលមាននៅក្នុងគល់បញ្ជីទាំងនេះ អាចបង្ហាញបានលុះត្រាតែមានការអនុញ្ញាតពី៖**
  - ច្បាប់
  - លិខិតបទដ្ឋានគតិយុត្ត ឬ
  - សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។



## សន្តិសុខទិន្នន័យ - មាត្រា១៦០-១៦២

- ការប្រមូល ការបញ្ជូន ការប្រើប្រាស់ និងការផ្ទុកទិន្នន័យអត្តសញ្ញាណបុគ្គល៖
  - ត្រូវធ្វើឡើងក្នុងលក្ខណៈមួយដែលធានាបាននូវសន្តិសុខ សុក្រឹតភាព សុចរិតភាពទិន្នន័យ និងការពារទិន្នន័យមិនឱ្យមានការប្រើប្រាស់ដោយគ្មានការអនុញ្ញាត និងបាត់បង់
- មន្ត្រីសាធារណៈអាចប្រើប្រាស់ទិន្នន័យអត្តសញ្ញាណបុគ្គលដែលចាំបាច់សម្រាប់បំពេញមុខងារសាធារណៈរបស់ខ្លួនប៉ុណ្ណោះ
- បញ្ជីអត្រានុកូលដ្ឋាន បញ្ជីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវរក្សាទុកជាអចិន្ត្រៃយ៍ នៅក្រសួងមហាផ្ទៃ
- បញ្ជីសញ្ជាតិ បញ្ជីលិខិតឆ្លងដែន បញ្ជីស្នាក់នៅ និងបញ្ជីអន្តោប្រវេសន៍ ត្រូវបានរក្សាទុកនៅក្រសួងមហាផ្ទៃ
- បញ្ជីប្រជាជន ត្រូវរក្សាទុកជាអចិន្ត្រៃយ៍ នៅមជ្ឈមណ្ឌលគ្រប់គ្រងអត្តសញ្ញាណប្រជាជន។





# ជំពូកទី៨.
# អំពីកម្រៃសេវា



## អំពីកម្រៃសេវា - មាត្រា១៦៣-១៦៥

- **សេវាដែលមិនតម្រូវឱ្យបង់កម្រៃ (មាត្រា១៦៤)៖**
  - សេវាចុះបញ្ជីកំណើតរស់ មរណភាព អាពាហ៍ពិពាហ៍ និងការកែតម្រូវកំហុសបច្ចេកទេសដោយមន្ត្រីអត្រានុកូលដ្ឋាន
  - សេវាចុះបញ្ជីតាមសេចក្តីសម្រេចរបស់តុលាការ
  - សេវាចុះបញ្ជីស្នាក់នៅ
  - សេវាផ្សេងទៀតដែលមិនត្រូវបង់កម្រៃ ត្រូវកំណត់ដោយអនុក្រឹត្យ។
- **សេវាដែលត្រូវបង់កម្រៃ (មាត្រា១៦៥)៖**
  - កម្រៃសេវាត្រូវកំណត់ដោយអនុក្រឹត្យ។



# ជំពូកទី៩.
# ការត្រួតពិនិត្យ និងអធិការកិច្ច



## ការត្រួតពិនិត្យ និងអធិការកិច្ច - មាត្រា១៦៦

- **ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ត្រូវរៀបចំបែបបទ លក្ខខណ្ឌ និងនីតិវិធី ដើម្បីត្រួតពិនិត្យ និងធ្វើអធិការកិច្ចជាប្រចាំទៅលើការងារ៖**
  - ចុះបញ្ជីអគ្រានុកូលដ្ឋាន
  - ស្ថិតិអត្រានុកូលដ្ឋាន
  - ការចុះបញ្ជីស្នាក់នៅ
  - អត្តសញ្ញាណកម្ម និង
  - ការងារដទៃទៀតដែលស្ថិតនៅក្រោមច្បាប់នេះ។





# ជំពូកទី១០.
# ទោសប្បញ្ញត្តិ

## ទោសប្បញ្ញត្តិ - មាត្រា១៦៧-១៧២

- ការមិនចុះបញ្ជីអត្រានុកូលដ្ឋាន និងបញ្ជីផ្សេងៗដោយចេតនារបស់មន្ត្រីចុះបញ្ជី ត្រូវផ្តន្ទាទោស**ដាក់ពន្ធនាគារពី១ខែ ទៅ២ឆ្នាំ និងពិន័យជាប្រាក់ពី១សែនរៀល ទៅ២លានរៀល**
- ការធ្វើឱ្យខូចខាត ឬបំផ្លាញ ឬធ្វើឱ្យបាត់បង់បញ្ជីអត្រានុកូលដ្ឋាន និងបញ្ជីផ្សេងៗដោយចេតនារបស់មន្ត្រីមានសមត្ថកិច្ច ត្រូវផ្តន្ទាទោស**ដាក់ពន្ធនាគារពី៥ឆ្នាំ ទៅ១០ឆ្នាំ**
- ការលុប ឬកែព័ត៌មាន ឬបញ្ចូលទិន្នន័យមិនពិតក្នុងបញ្ជីអត្រានុកូលដ្ឋាន និងបញ្ជីផ្សេងៗរបស់មន្ត្រីមានសមត្ថកិច្ច ត្រូវផ្តន្ទាទោស**ដាក់ពន្ធនាគារពី៥ឆ្នាំ ទៅ១០ឆ្នាំ**
- ការចូលដល់បញ្ជីអត្រានុកូលដ្ឋាន និងបញ្ជីផ្សេងៗដោយចេតនារបស់មន្ត្រីមានសមត្ថកិច្ច ត្រូវផ្តន្ទាទោស**ដាក់ពន្ធនាគារពី៦ខែ ទៅ២ឆ្នាំ និងពិន័យជាប្រាក់១លានទៅ៤លានរៀល**
- អំពើប្រព្រឹត្តដូចករណីខាងលើ បណ្តាលឱ្យខូចខាតដល់បញ្ជី ឬប្រព័ន្ធប្រព្រឹត្តកម្មត្រូវផ្តន្ទាទោស**ដាក់ពន្ធនាគារពី២ឆ្នាំ ទៅ៥ឆ្នាំ និងពិន័យជាប្រាក់៤លាន ទៅ១០លានរៀល**
- បុគ្គលផ្តល់ព័ត៌មាន ឬឯកសារក្លែងក្លាយដោយចេតនាសម្រាប់ការចុះបញ្ជី ការកត់ត្រា ឬការជូនដំណឹង ត្រូវផ្តន្ទាទោស**ដាក់ពន្ធនាគារពី១ខែទៅ៦ខែ និងពិន័យជាប្រាក់ពី១លាន ទៅ៣លានរៀល**
- បុគ្គលក្លែងបន្លំ ឬកែសំបុត្រអត្រានុកូលដ្ឋាន សៀវភៅស្នាក់នៅ ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ឬសម្រង់នៃបញ្ជីអត្រានុកូលដ្ឋាន ឬបញ្ជីស្នាក់នៅ ឬបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬបញ្ជីប្រជាជនដោយចេតនា ត្រូវផ្តន្ទាទោស**ដាក់ពន្ធនាគារពី៥ឆ្នាំ ទៅ១០ឆ្នាំ។**






## ជំពូកទី១១.
## អន្តរប្បញ្ញត្តិ



## អន្តរប្បញ្ញត្តិ - មាត្រា១៧៣-១៧៦

- នៅពេលច្បាប់នេះមានអានុភាពអនុវត្ត លិខិតបទដ្ឋាននានាពាក់ព័ន្ធនឹង**ការចុះបញ្ជីអត្រានុកូលដ្ឋាន ការចុះបញ្ជីស្នាក់នៅ ការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងស្ថិតិអត្រានុកូលដ្ឋាន** ដែលកំពុងអនុវត្ត នៅតែមានអានុភាពអនុវត្តបន្តរហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស **លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងច្បាប់នេះ**
- **ព្រឹត្តិការណ៍កំណើតរស់ ឬមរណភាព**ដែលបានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ ប៉ុន្តែមិនទាន់បានដាក់ពាក្យសុំចុះបញ្ជីត្រឹមកាលបរិច្ឆេទនៃការអនុវត្ត **ត្រូវធ្វើការចុះបញ្ជីតាមបទប្បញ្ញត្តិនៃច្បាប់នេះ**
- **សេចក្តីសម្រេចរបស់តុលាការទាំងឡាយណា**ដែលទាក់ទងនឹងការចុះបញ្ជីអត្រានុកូលដ្ឋានដូចជាការលែងលះ បិតុភាព មាតុភាព សុំកូន ការផ្តាច់មត៌ក និងការកែកំហុសនានា ដែលបានចូលជាស្ថាពរមុនកាលបរិច្ឆេទអនុវត្តជាទូទៅ ប៉ុន្តែមិនទាន់បានរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច អាចរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចបាន
- **សេចក្តីសម្រេចរបស់តុលាការទាំងឡាយណា**ដែលទាក់ទងនឹងការប្តូរឈ្មោះដែលបានចូលជាស្ថាពរមុនកាលបរិច្ឆេទអនុវត្តជាទូទៅ ប៉ុន្តែមិនទាន់បានរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋាន។

# ជំពូកទី១២.
# អវសានប្បញ្ញត្តិ



## អវសានប្បញ្ញត្តិ - មាត្រា១៧៧-១៨២

- **កំណត់ត្រាបញ្ជីអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ និងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ** ដែលបានធ្វើឡើងមុនកាលបរិច្ឆេទអនុវត្តជាទូទៅនៃច្បាប់នេះ ត្រូវបន្តមានសុពលភាព
- ច្បាប់នេះ ត្រូវអនុវត្តភ្លាមនៅកាលបរិច្ឆេទដែល**រយៈពេល១២ខែ** ក្រោយពេលច្បាប់នេះចូលជាធរមាន ហៅថាកាលបរិច្ឆេទអនុវត្តជាទូទៅ (ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ កក្កដា ឆ្នាំ២០២៤)
- ក្រោយកាលបរិច្ឆេទអនុវត្តជាទូទៅនៃច្បាប់នេះ កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិទាក់ទងនឹង **អាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន មជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន និងប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន ការជូនដំណឹងដោយវិស័យសុខាភិបាល និងការបញ្ជាក់អំពីមូលហេតុនៃមរណភាព និងការជូនដំណឹងដោយតុលាការ** ត្រូវកំណត់ដោយអនុក្រឹត្យ
- **បទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត**ដែលមានអានុភាពនៅពេលច្បាប់នេះត្រូវបានអនុវត្ត ប៉ុន្តែផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ **ត្រូវចាត់ទុកថាគ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងច្បាប់នេះ។**





សូមអរគុណ...!